# របាយការណ៍

## សិក្ខាសាលាថ្នាក់តំបន់ “ ពិនិត្យមើលលទ្ធផលនៃការស្វែងរកអ្នកផ្ទុកមេរោគអេដស៍ និងការពង្រឹងគុណភាពនៅសេវាថែទាំ និងព្យាបាលទៅតាមវដ្តការធ្វើផែនការ-ការអនុវត្ត-ការពិនិត្យមើល-ការកែតម្រូវសកម្មភាព ”

Regional Workshop to “Review the Results of Interlink Active Case Management and Continuous Quality Improvement (IACM-CQI)”

ថ្ងៃអង្គារ ១០រោច ដល់ថ្ងៃពុធ ១១រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព២៥៦៨ .ស.

**ត្រូវនឹងថ្ងៃទី៣០ ដល់ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០២៤ ខេត្តកំពត**



**រៀបចំដោយ**

**ឧបត្ថម្ភដោយ**

US CDC Cambodia

# របាយការណ៍

## សិក្ខាសាលាថ្នាក់តំបន់ “ ពិនិត្យមើលលទ្ធផលនៃការស្វែងរកអ្នកផ្ទុកមេរោគអេដស៍ និងការពង្រឹងគុណភាពនៅសេវាថែទាំ និងព្យាបាលទៅតាមវដ្តការធ្វើផែនការ-ការអនុវត្ត-ការពិនិត្យមើល-ការកែតម្រូវសកម្មភាព ”

Regional Workshop to "Review the Results of Interlink Active Case Management and Continuous Quality Improvement (IACM-CQI)"

### ១. គោលបំណង៖

**គោលបំណងរួម៖**

- ដើម្បីធានានូវសមាមាត្រខ្ពស់នៃល្បាក់ទាំងមូល ចាប់តាំងពីការរកឃើញអ្នកផ្ទុកមេរោគអេដស៍ រហូតដល់ការចុះឈ្មោះនិងទទួលបានសេវាថែទាំនិងព្យាបាលប្រកបដោយគុណភាព។

**គោលបំណងជាក់លាក់៖**

- **ពិនិត្យលទ្ធផលសម្រេចបាននៃសូចនាករ៖**

  សូចនាករសំខាន់ៗ ៦ របស់ ACM

1. ចំនួនករណីប្រតិកម្មរកឃើញថ្មី ( reactive cases )
2. ចំនួនករណីប្រតិកម្មថ្មីមានតេស្តបញ្ជាក់វិជ្ជមាន ( confirmed HIV+ )
3. % recency test ( RTRI ) វិជ្ជមាន
4. % អ្នកមានតេស្តបញ្ជាក់វិជ្ជមានចុះឈ្មោះក្នុងសេវាART
5. % អ្នកចុះឈ្មោះក្នុងសេវាARTបានទទួលនិងចាប់ផ្តើមART

សូចនាការនៃសេវាថែទាំនិងព្យាបាលប្រកបដោយគុណភាព

1. % អ្នកជំងឺART ដែលបានស្លាប់
2. % អ្នកជំងឺARTខកណាត់ ≤28ថ្ងៃដែលបានដាក់ឱ្យទទួលសេវាវិញ
3. % អ្នកជំងឺបាត់មុខ >28ថ្ងៃ ដែលបានដាក់ឱ្យទទួលសេវាវិញ
4. % ការមកពិនិត្យតាមការណាត់, មុនថ្ងៃណាត់, យឺតនៅថ្នាំបម្រុង, យឺតអស់ថ្នាំបម្រុង
5. % អ្នកជំងឺផ្តើមARTថ្មីនៅក្នុងត្រីមាសដែលចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ក្នុងថ្ងៃតែមួយនឹងថ្ងៃធ្វើរោគវិនិច្ឆ័យថាមានផ្ទុកមេរោគអេដស៍

6. % អ្នកជំងឺបាននិងកំពុងទទួលឱសថនិងការណាត់ជួប ≥3 months

7. % អ្នកជំងឺផ្តើមARTថ្មីដំបូងដោយឱសថTLD

8. % អ្នកជំងឺសរុបបានទទួល ឱសថ TLD មកទល់នឹងចុងត្រីមាសរាយការណ៍

9. % អ្នកជំងឺដែលសមស្របធ្វើVL តេស្តនៅក្នុងត្រីមាស បានធ្វើVLតេស្ត

10. % លទ្ធផលVLតេស្តបានត្រឡប់មកដល់គ្លីនិកវិញក្នុងអំឡុងពេល១០ថ្ងៃ

11. % អ្នកជំងឺ on ARTបានធ្វើតេស្តVL ក្នុងអំឡុងពេល១២ខែកន្លងមក ( VL testing coverage )

12. % អ្នកជំងឺ on ARTមានVL suppressed ( WHO VLS.3 program-level denominator )

13. % អ្នកជំងឺ on ARTមានVL suppressed ( WHO VLS.3 population-level denominator )

14. % អ្នកជំងឺដែលបានបញ្ចប់TPT នៅចុងត្រីមាសរាយការណ៍

15. អត្រាអ្នកជំងឺបន្តបិតនៅក្នុងសេវាARTរបស់យើង Retention rate

16. ចំនួនលទ្ធផល Viral Load Test បានទទួលតាមត្រីមាសនីមួយៗ បែងចែកតាម ប្រភេទ <40, 40-999, and 1000+ ឆ្នាំ ២០២១២០២៣-

17. បច្ចុប្បន្នភាព ការពង្រឹង EAC ករណីអ្នកជំងឺដែលមានViral Load 40-999 និង ≤1000

- **កំណត់បញ្ហាអាទិភាព និងមូលហេតុដែលបណ្តាលឱ្យលទ្ធផលរបស់សូចនាករធ្លាក់ចុះ**
- **រៀបចំផែនការសកម្មភាពដើម្បីកែលម្អ**

## ២. លទ្ធផល

នាថ្ងៃអង្គារ ១០រោច ដល់ថ្ងៃពុធ ១១រោច ខែាអាសាឍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹងថ្ងៃទី៣០ ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤ ខេត្តកំពត មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានរៀបចំសិក្ខាសាលាថ្នាក់តំបន់ពិនិត្យមើលលទ្ធផលនៃការស្វែងរកអ្នកផ្ទុកមេរោគអេដស៍ និងការពង្រឹង គុណភាពនៅសេវាថែទាំ និងព្យាបាលទៅតាមវដ្ត ការធ្វើផែនការ ការអនុវត្ត-ការពិនិត្យមើល-ការកែតម្រូវសកម្មភាព ក្រោមការឧបត្ថមថវិកា US CDS Cambodia នៅមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកំពត។



វគ្គសិក្ខានេះក្រោមអធិបតីភាពរបស់លោកវេជ្ជ. ង៉ូវ បូរ៉ា អនុប្រធានមជ្ឍមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ តំណាងដ៏ខ្ពង់ខ្ពស់របស់លោកសាស្ត្រាចារ្យជំនួយ អ៊ុក វិជ្ជា ប្រធានមជ្ឍមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានដឹកនាំសិក្ខាសាលាថ្នាក់តំបន់ពិនិត្យមើលលទ្ធផលនៃការស្វែងរកអ្នកផ្ទុកមេរោគអេដស៍ និងការពង្រឹងគុណភាពសេវាថែទាំ និងព្យាបាលទៅតាមវដ្តការធ្វើផែនការ-ការអនុវត្ត-ការពិនិត្យមើល-ការកែតម្រូវសកម្មភាព ដែលប្រព្រឹត្តទៅនៅមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកំពត ឧបត្ថម្ភថវិកាដោយ US CDC Cambodia ក្នុងវគ្គសិក្ខាសាលានោះក្រោមអធិបតីភាពរបស់លោកវេជ្ជ. ង៉ូវ បូរ៉ា អនុប្រធានមជ្ឍមណ្ឌលជាតិប្រយទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ លោកវេជ្ជ. តាន់ ឆេង អនុប្រធានមន្ទីរសុខាភិបាលខេត្តកំពត លោកវេជ្ជ. ចាន់ សូដារា អនុប្រធានមជ្ឍមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក តំណាងអោយគម្រោង US CDC Cambodia រួមជាមួយអ្នកចូលរួមជា ប្រធានកម្មវិធីអេដស៍ ប្រធានផ្នែកសេវាថែទាំ និងបង្ការជំងឺអេដស៍ តាមមន្ទីរសុខាភិបាលខេត្ត មន្ទីរពេទ្យខេត្ត និងមន្ទីរពេទ្យបង្អែក តំណាងស្ថាប័នម្ចាស់ជំនួយ អង្គការពាក់ព័ន្ធ នានា មកពីរាជធានីខេត្ត សរុបចំនួន ៤៨ នាក់ និងអង្គការដៃគូ CRS RHAC AHF។ បន្ទាប់ពីកិច្ចស្វាគមន៍ មតិចំណាប់អារម្មណ៍ និងប្រកាសបើកវគ្គរបស់គណៈអធិបតីរួចមក ក្រុមការងារបានអញ្ជើញគណៈអធិបតី និងសិក្ខាកាមទាំងអស់ចូលរួម និងថតរូបអនុស្សាវរីយ៍។ បន្ទាប់មកក្រុមការងារបានបង្ហាញពីគោលបំណង របៀបវារៈ និងការបង្ហាញរបស់តំណាងខេត្តនិមួយៗ ទៅតាមកម្មវិធីដែលបានគ្រោងទុក។






